ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០១៧ ព.ណ. ៨៥៦២

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន លោក-លោកស្រីជាម្ចាស់ម៉ាក ឬជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកទាំងអស់ មេត្តាជ្រាបថា: យោងតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា ៥៨ និងមាត្រា ៥៩ និងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា ៧ និងមាត្រា ១៦ **រាល់សំណុំឯកសារដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវតែជាច្បាប់ដើម និងបំពេញលក្ខខ័ណ្ឌចំនួន ៥ចំណុច** ដូចមានចែងខាងក្រោម:

ក- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ខ- អាស័យដ្ឋានទំនាក់ទំនង

គ- គំរូម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- យថាប្រភេទរបស់ទំនិញឬសេវា ដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ

ង- កំរៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវា ដែលសុំចុះបញ្ជីម៉ាក។

ក្រសួងពាណិជ្ជកម្មនឹងចេញលេខ និងកាលបរិច្ឆេទដាក់ពាក្យសុំចុះបញ្ជីម៉ាកជូន ក្រោយពេលអ្នកស្នើសុំបានបំពេញគ្រប់លក្ខខ័ណ្ឌខាងលើ។

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឲ្យធ្វើការដាក់ពាក្យអាចភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះទៅឲ្យមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ០២(ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង និងធ្វើឡើងមិនសមស្របតាមមាត្រា ៥៨ និងមាត្រា ៥៩ នៃច្បាប់

និងមាត្រា ២៨ នៃអនុក្រឹត្យនេះទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជីនឹងមិនត្រូវធ្វើឡើងទ្បើយ។

បើផ្ទុយពីខ្លឹមសារ និងលក្ខខ័ណ្ឌដូចមានចែងខាងលើ ក្រសួងពាណិជ្ជកម្មនឹងមិនអនុញ្ញាតឲ្យទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកទ្បើយ។

សេចក្ដីជូនដំណឹងនេះ នឹងមានអានុភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីជាម្ចាស់ម៉ាក ឬជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ជ្រាបជាព័ត៌មានតាមការគួរ។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**